# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា
# <u>សាលាបឋមសិក្សា ឃើកប្រាយ (KIRKBRIDE)</u>
# ច្បាប់ស្តីពីការចូលរួមរបស់មាតាបិតា
# ២០១៤-២០១៥

## <u>ផ្នែកទី I</u> <u>បំណងប្រាថ្នាជាទូទៅ</u>

សាលានីមួយៗ នៅក្នុងច្បាប់ស្តីពីការចូលរួមរបស់មាតាបិតា ទូទាំងសាលា ត្រូវរៀបចំបង្កើតបំណងប្រាថ្នារបស់សាលា សម្រាប់ការចូលរួមរបស់មាតាបិតា។ *[Section 1118(a)(2), ESEA.]*

<u>សាលាបឋមសិក្សា ឃើកប្រាយ</u> យល់ព្រមអនុវត្តនូវលក្ខន្តិកៈ តាមតម្រូវការដូចតទៅនេះ៖

- ក្រសួងអប់រំនឹងចាប់ផ្តើមប្រតិបត្តិនូវ កម្មវិធី សកម្មភាព និងនីតិវិធី ផ្សេងៗ សម្រាប់ការចូលរួមរបស់មាតាបិតា នៅសាលាទាំងអស់របស់ក្រសួងអប់រំ ដែលស្របតាមមាត្រាលេខ១១១៨ នៃច្បាប់អប់រំ សាលាបឋមសិក្សា និងវិទ្យាល័យ (Elementary and Secondary Education Act, ESEA) កម្មវិធី Title I, Part A។ កម្មវិធី សកម្មភាព និងនីតិវិធី ទាំងនោះ ត្រូវរៀបចំ និងធ្វើឡើងតាមការប្រឹក្សាដ៏មានន័យជាមួយ មាតាបិតា/អាណាព្យាបាល របស់ក្មេងដែលចូលរួម។

- ដើម្បីឲ្យស្របតាមមាត្រាលេខ១១១៨ ក្រសួងអប់រំនឹងសហការជាមួយសាលាទាំងអស់របស់ក្រសួង ដើម្បីធ្វើយ៉ាងណាឲ្យការតម្រូវនៃច្បាប់ចូលរួមរបស់មាតាបិតានៅតាមសាលា ត្រូវតាមការតម្រូវរបស់មាត្រាលេខ១១១៨(b) នៃច្បាប់ ESEA ហើយច្បាប់នីមួយៗមានបញ្ចូល កិច្ចសន្យារវាងមាតាបិតា និង សាលា ដែលស្របទៅតាមមាត្រាលេខ១១១៨(d) នៃច្បាប់ ESEA។

- ក្រសួងអប់រំនឹងបញ្ចូលច្បាប់ចូលរួមរបស់មាតាបិតាទូទាំងក្រសួងនេះ ទៅក្នុងគម្រោងការរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា ដែលបានបង្កើតឡើងក្រោមមាត្រាលេខ១១១២ នៃច្បាប់ ESEA។

- ក្នុងការអនុវត្តន៍ច្បាប់ Title I, Part A ការតម្រូវនៃការចូលរួមរបស់មាតាបិតា តាមការដែលអាចធ្វើទៅបាន ក្រសួងអប់រំ និងសាលាទាំងអស់ នឹងផ្តល់ឱកាសចូលរួមយ៉ាងពេញលេញដល់ មាតាបិតាដែលចេះភាសាអង់គ្លេសតិចតួច មាតាបិតាដែលពិការ និង មាតាបិតារបស់ក្មេងដែលផ្លាស់ប្តូរទីកន្លែងរស់នៅដោយសារការងាររបស់មាតាបិតា រួមទាំងការផ្តល់ព័ត៌មាន និងរបាយការណ៍នៃការសិក្សា ដែលបានតម្រូវនៅក្នុងមាត្រាលេខ១១១១ នៃច្បាប់ ESEA តាមរបៀបដែលអាចមើលយល់ និង មានទម្រង់ដូចគ្នា ហើយរួមទាំងទម្រង់ផ្សេងទៀតតាមការស្នើសុំ និងតាមតែអាចធ្វើទៅបាន ជាភាសាដែលមាតាបិតាអាចយល់។

- បើសិនជាផែនការរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា សម្រាប់ Title I, Part A បានបង្កើតឡើងក្រោមមាត្រាលេខ១១១២ នៃច្បាប់ ESEA មានការមិនពេញចិត្តពីសំណាក់មាតាបិតារបស់ក្មេងដែលចូលរួម ក្រសួងអប់រំនឹងផ្តល់មតិយោបល់របស់មាតាបិតាជាមួយនឹងផែនការនោះ នៅពេលក្រសួងអប់រំផ្តល់គម្រោងការទៅឲ្យ ក្រសួងអប់រំរបស់រដ្ឋ។

- ក្រសួងអប់រំនឹងផ្តល់ឲ្យមានការចូលរួមពីមាតាបិតារបស់ក្មេងរៀននៅសាលាដែលផ្តល់កម្មវិធីនៃច្បាប់ Title I, Part A ក្នុងការសម្រេចនូវរបៀបចំណាយប្រាក់ឧបត្ថម្ភ១ភាគរយរបស់ច្បាប់ Title I, Part A សម្រាប់ការចូលរួមរបស់មាតាបិតា ហើយនឹងធ្វើយ៉ាងណាមិនឲ្យតិចជាង៩៥ភាគរយនៃប្រាក់ជំនួយ១ភាគរយនេះ ត្រូវចំណាយទៅលើសាលាផ្ទាល់។

- ក្រសួងអប់រំត្រូវគោរពធ្វើតាមនិយមន័យនៃលក្ខន្តិកៈ អំពីការចូលរួមរបស់មាតាបិតា ដូចតទៅនេះ ហើយសង្ឃឹមថា សាលាទាំងអស់ដែលទទួលការឧបត្ថម្ភពីច្បាប់ Title I នឹងមាន កម្មវិធី សកម្មភាព និង វិធីសាស្ត្រផ្សេងៗ ដែលស្របតាមនិយមន័យនេះ៖

  ការចូលរួមរបស់មាតាបិតា មានន័យថា ជាការចូលរួមរបស់មាតាបិតាជាធម្មតា ទៅវិញទៅមក និងទំនាក់ទំនងដ៏មានអត្ថន័យ ដែលទាក់ទងដល់ការសិក្សារបស់សិស្សានុសិស្ស និង សកម្មភាពសាលាផ្សេងៗទៀត រួមទាំងការបញ្ជាក់ថា—

(ក) មាតាបិតា មានមុខនាទីដ៏សំខាន់ ក្នុងការជួយដល់ការសិក្សារបស់កូន

(ខ) មាតាបិតា ត្រូវទទួលការលើកទឹកចិត្តឲ្យចូលរួមដោយសកម្មក្នុងនៃការសិក្សារបស់កូននៅសាលា

(គ) មាតាបិតា ជាដៃគូយ៉ាងពេញលេញក្នុងការសិក្សារបស់កូន ហើយតាមលក្ខណៈសមស្រប រួមទាំង ការចូលរួមសម្រេចចិត្ត និង ជាផ្នែកនៃក្រុមប្រឹក្សា ដើម្បីជួយដល់ការសិក្សារបស់ក្មេង

(ឃ) ការអនុវត្តន៍នូវសកម្មភាពផ្សេងៗ ដូចជាអ្វីៗដែលបានរៀបរាប់ក្នុងមាត្រា១១១៨ នៃច្បាប់ ESEA។

- ក្រសួងអប់រំនឹងជូនដំណឹងដល់មាតាបិតា និងអង្គការមាតាបិតា អំពីគោលបំណង ព័ត៌មាន និង មណ្ឌលផ្តល់ព័ត៌មាន សម្រាប់មាតាបិតា នៅក្នុងរដ្ឋ។

## <u>ផ្នែកទី II</u> <u>ការរៀបរាប់អំពីវិធីដែលសាលាអនុវត្តច្បាប់នៃការចូលរួមរបស់មាតាបិតាទូទាំងក្រសួងតាមការតម្រូវ</u>

[កំណត់សម្គាល់៖ ច្បាប់នៃការចូលរួមរបស់មាតាបិតាទូទាំងសាលា ត្រូវរួមបញ្ចូលការពិពណ៌នាអំពីវិធីដែលសាលានឹង អនុវត្ត ឬ សម្រេចបាននូវអ្វីទាំងអស់ដូចតទៅនេះ។ *[មាត្រាលេខ ១១១៨(a)(2), ESEA]* ដោយមិនគិតពីទម្រង់ដែលសាលាជ្រើសយក ការពិពណ៌នានីមួយៗត្រូវរួមបញ្ចូលនូវចំណុចខាងក្រោមនេះ ដើម្បីឲ្យត្រូវតាមតម្រូវការរបស់លក្ខន្តិកៈ។]

**១.** **<u>សាលា យើងប្រាប</u>** នឹងធ្វើសកម្មភាពដូចតទៅនេះ ដើម្បីឲ្យមាតាបិតាចូលរួមសហការក្នុងការអភិវឌ្ឍន៍ គម្រោងផែនការចូលរួមរបស់មាតាបិតាទូទាំងសាលា នៅក្រោមមាត្រាលេខ១១១២ នៃច្បាប់ ESEA៖

**គេនឹងអញ្ជើញមាតាបិតាឲ្យចូលរួមក្នុងការរៀបចំគម្រោងផែនការសម្រាប់ការចូលរួមរបស់មាតាបិតា នៅរដូវផ្ការីក។ គេនឹងផ្ញើច្បាប់ចម្លងនៃផែនការនេះទៅមាតាបិតាទាំងអស់។**

**២.** **<u>សាលា យើងប្រាប</u>** នឹងធ្វើសកម្មភាពដូចតទៅនេះ ដើម្បីឲ្យមាតាបិតាចូលរួមសហការក្នុង វិធីពិនិត្យ និង កែលម្អ សាលា ក្រោមមាត្រាលេខ១១១៦ នៃច្បាប់ ESEA៖

**គេនឹងអញ្ជើញមាតាបិតាឲ្យចូលរួមក្នុងការរៀបចំគម្រោងផែនការសម្រាប់ការចូលរួមរបស់មាតាបិតា នៅរដូវផ្ការីក។ គេនឹងផ្ញើច្បាប់ចម្លងនៃផែនការនេះទៅមាតាបិតាទាំងអស់។**

**៣.** **<u>ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា</u>** នឹងផ្តល់អ្វីៗដែលចាំបាច់ដូចតទៅនេះ ការសម្របសម្រួល ជំនួយបច្ចេកទេស និងជំនួយផ្សេងៗទៀត ដើម្បីជួយសាលាដែលទទួលជំនួយពីច្បាប់ Title I, Part A ក្នុងការរៀបចំគម្រោងការ និង ការអនុវត្តន៍សកម្មភាព ឲ្យមានប្រសិទ្ធិភាព សម្រាប់ការចូលរួមរបស់មាតាបិតា ដើម្បីបង្កើនជោគជ័យនៃការសិក្សារបស់សិស្ស និង កែលម្អការបង្ហាត់បង្រៀនរបស់សាលា៖

- តាមការសហការជាមួយ អ្នកត្រួតពិនិត្យផ្នែកតម្រូវការនៃប្រាក់ជំនួយ អ្នកទាក់ទងផ្នែកគាំទ្រការកែលម្អសាលានៅតាមសាលា អ្នកទាក់ទងរវាងសហគមន៍និងសាលា ក្រុមប្រឹក្សាមាតាបិតានិងសាលា នៃទីក្រុងហ្វីឡាដែលហ្វ្យា (PHSC) ក្រុមប្រឹក្សាមាតាបិតាផ្នែកច្បាប់ Title I ក្រុមការងារផ្នែកសិទ្ធិយល់ដឹងអំពីការអប់រំ នៃទីក្រុងហ្វីឡាដែលហ្វ្យា សិទ្ធិអំណាចរបស់មាតាបិតា (PARENT POWER) និងក្រុមមាតាបិតាផ្សេងៗទៀត ផ្តល់សិក្ខាសាលាដល់សាលា អំពីការចូលរួមរបស់មាតាបិតា។
- ផ្តល់ការហ្វឹកហ្វឺនផ្នែកការងារ <u>ដោយមាតាបិតា/អាណាព្យាបាល</u> សម្រាប់នាយកសាលា ថ្មី និង ចាស់ និង រដ្ឋបាលផ្សេងទៀត អំពីវិធីអភិវឌ្ឍ ដៃគូដែលមានការសន្យា ជាមួយ មាតាបិតា/អាណាព្យាបាល។
- បង្វឹកបុគ្គលិក ថ្មី និង ចាស់ អំពីកាតព្វកិច្ចនៃការចូលរួមរបស់មាតាបិតា (ឧ. អ្នកទាក់ទងផ្នែកផ្តល់ជំនួយដល់ការកែលម្អសាលា អ្នកទាក់ទងរវាងសាលា និង សហគមន៍ អ្នកសម្របសម្រួលផ្នែកសហគមន៍សាលា និង អ្នកជំនួយការខាងផ្តល់ឱវាទដែលចេះពីរភាសា) ដើម្បីជួយនៅសាលាក្នុងការបង្កើតឲ្យមានការចូលរួមពីមាតាបិតា។

- រៀបចំឲ្យមានបុគ្គលិកនៅ ការិយាល័យសមភាពផ្នែកអប់រំ ការិយាល័យផ្នែកកម្មវិធីសិក្សាពិសេស និង ការិយាល័យទំនាក់ទំនងជាមួយ ក្រុមគ្រួសារ និង សហគមន៍ និង បុគ្គលិករបស់អគ្គនាយករង ដើម្បីផ្តល់ជំនួយបច្ចេកទេស។
- ការិយាល័យផ្នែក Title I នឹងផ្តល់ជំនួយបច្ចេកទេសដល់សាលា និងអង្គការមាតាបិតា ដូចជា ក្រុមប្រឹក្សាមាតាបិតា (PAC) ផ្នែកច្បាប់ Title I សមាគម មាតាបិតា និងសាលា ក្រុមការងារផ្នែកសិទ្ធិនៃការអប់រំ នៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា សិទ្ធិអំណាចរបស់មាតាបិតា និង ក្រុមដែលរៀបចំដោយមាតាបិតា ផ្សេងៗទៀត។
- ផ្តល់ការរៀបចំដល់ការហ្វឹកហ្វឺនផ្នែកការងារ តាមរយៈ ការិយាល័យជំនួយផ្នែក បង្ហាត់បង្រៀន និង ការដឹកនាំ។
- ផ្តល់សិក្ខាសាលាដល់មាតាបិតាអំពីការគាំទ្រដល់ជោគជ័យរបស់សិស្ស និង ការចូលរួមរបស់មាតាបិតា។
- ផ្តល់ ការហ្វឹកហ្វឺន និង ព័ត៌មានផ្សេងៗ ដល់ក្រុមប្រឹក្សាសាលា។ ដល់ខែវិច្ឆិកា ២០១១ ក្រុមប្រឹក្សាសាលានីមួយៗ នឹងរៀបចំគម្រោងអំពីវិធីសហការជាមួយមាតាបិតាផ្នែក ច្បាប់ Title I PREP ដើម្បីរៀបចំកម្មវិធីត្រឡប់មកហ្វឹកហ្វឺនដល់មាតាបិតាទាំងអស់នៅសាលារបស់ពួកគាត់។
- មាតាបិតា PREP តាមតំបន់ នឹងធ្វើជាទីប្រឹក្សារបស់ នាយកសាលា និងជាសមាជិកក្រុមប្រឹក្សាសាលា អំពីវិធីដោះស្រាយនូវសេចក្តីត្រូវការរបស់សិស្សានុសិស្ស និង មាតាបិតា ដែលមាននៅក្នុង គម្រោងផែនការ និង ថវិកា Title I របស់សាលាពួកគាត់។
- ដើម្បីឲ្យស្របតាម ការគិតដល់ឆ្នាំ២០១៤ គេជួយដល់មាតាបិតា និង ក្រុមគ្រួសារ មានឱកាសជួបជាមួយ គ្រូ និង នាយកសាលា។

៤. **<u>សាលា យើងប្រាយ</u>** នឹងចាត់ចែង និង រួមបញ្ចូលវិធីសាស្ត្រនៃការចូលរួមរបស់មាតាបិតានៅក្នុង Part A ជាមួយនឹងវិធីសាស្ត្រនៃការចូលរួមរបស់មាតាបិតា ក្នុងកម្មវិធីផ្សេងៗ ដូចតទៅនេះ៖

***** កម្មវិធី** Head Start

***** ផ្តល់ដំណឹងជូនដល់មាតាបិតាអំពីសកម្មភាពរបស់សាលា ជាភាសាដែលនិយាយនៅផ្ទះ ទាំងអស់**

៥. **<u>សាលា យើងប្រាយ</u>** នឹងធ្វើសកម្មភាពដូចតទៅ ជាមួយនឹងការចូលរួមពីមាតាបិតា ដើម្បីធ្វើការវាយតម្លៃប្រចាំឆ្នាំ អំពី ច្បាប់ និង ប្រសិទ្ធិភាព នៃច្បាប់ចូលរួមរបស់មាតាបិតានេះ ដើម្បីបង្កើនគុណភាពនៃកម្មវិធី Title I, Part A។ ការវាយតម្លៃនឹងមានរួមបញ្ចូលការរកឃើញឧបសគ្គដែលរារាំងមិនឲ្យ មាតាបិតាចូលរួម ឲ្យបានច្រើន (ជាពិសេសចំពោះមាតាបិតាដែល ក្រខ្សត់ ពិការ មិនសូវចេះភាសាអង់គ្លេស មិនសូវចេះអក្សរ ឬ ជាសាសន៍ ឬ ជនជាតិភាគតិច)។ សាលានឹងប្រើលទ្ធផលដែលបានមកពីការវាយតម្លៃ នៃការចូលរួមរបស់មាតាបិតា និង សកម្មភាពផ្សេងៗ ដើម្បីរៀបចំវិធីនៃការចូលរួមរបស់មាតាបិតាឲ្យកាន់តែមានប្រសិទ្ធិភាព និងដើម្បីធ្វើការកែសម្រួលច្បាប់នៃការចូលរួមរបស់មាតាបិតាឡើងវិញ (ដោយមានការចូលរួមពីសំណាក់មាតាបិតា) បើសិនចាំបាច់។

**គេនឹងជូនដំណឹងដល់មាតាបិតាអំពីថ្ងៃប្រជុំ ជាភាសាដែលនិយាយនៅផ្ទះទាំងអស់ និងសូមអញ្ជើញមាតាបិតាមកចូលរួមក្នុងអង្គប្រជុំ។**

៦. **<u>សាលា យើងប្រាយ</u>** នឹងពង្រីកទំហំនៃការចូលរួមរបស់មាតាបិតានៅសាលា ឲ្យបានកាន់តែខ្លាំងឡើង ដើម្បីធ្វើយ៉ាងណាឲ្យការចូលរួមរបស់មាតាបិតាមានប្រសិទ្ធិភាព និងដើម្បីជួយគាំទ្រដល់ការសហការវាង សាលា មាតាបិតា និង សហគមន៍ ដើម្បីកែលម្អការរីកចម្រើននៃការសិក្សារបស់សិស្ស តាមរយៈសកម្មភាពដែលបានរៀបរាប់ដូចតទៅនេះ៖

ក. **<u>សាលា យើងប្រាយ</u>** ដោយមានជួយជ្រោមជ្រែងពីក្រសួងអប់រំ នឹងផ្តល់ជំនួយដែលសមរម្យដល់មាតាបិតា ក្នុងប្រធានបទដែលអាចយល់បាន ដូចតទៅ ដោយធ្វើតាមសកម្មភាពដែលបានរៀបរាប់នៅក្នុងប្រវគ្គនេះ --

- មុខវិទ្យាសិក្សាតាមខ្នាតគំរូរបស់រដ្ឋ
- ជោគជ័យនៃការសិក្សារបស់សិស្សតាមខ្នាតគំរូរបស់រដ្ឋ
- ការវាយតម្លៃនៃការសិក្សារបស់រដ្ឋ និងតំបន់ រួមទាំងការវាយតម្លៃតាមវិធីផ្សេងៗទៀត
- ការតម្រូវរបស់ច្បាប់ Title I, Part A
- វិធីតាមដានការរីកចម្រើនរបស់កូន និង
- វិធីសហការជាមួយអ្នកអប់រំ

ខ. <u>**សាលា យើងប្រាយ**</u> ដោយមានការជួយជ្រោមជ្រែងពីក្រសួងអប់រំ នឹងផ្តល់ សម្ភារៈ និង ការហ្វឹកហ្វឺន ដើម្បីជួយមាតាបិតាឲ្យជួយដល់កូនរបស់ពួកគាត់ពង្រីកជោគជ័យក្នុងការសិក្សា ដូចជាការហ្វឹកហ្វឺនផ្នែកអក្សរសាស្ត្រ និងការប្រើបច្ចេកវិទ្យា ទៅតាមលក្ខណៈសមរម្យ ដើម្បីជំរុញដល់ការចូលរួមរបស់មាតាបិតា ដោយ៖

**រៀបចំសិក្ខាសាលាសម្រាប់មាតាបិតា អំពីប្រធានបទផ្សេងៗ ដែលអាចជួយគាំទ្រដល់ការបង្ហាត់បង្រៀននៅផ្ទះ។ គេនឹងផ្តល់សម្ភារៈ ដើម្បីឲ្យមាតាបិតាជួយដល់ការសិក្សារបស់កូននៅផ្ទះ។**

គ. <u>**សាលា យើងប្រាយ**</u> ដោយមានការជួយជ្រោមជ្រែងពីក្រសួងអប់រំ នឹងអប់រំគ្រូ បុគ្គលិកដែលបម្រើសិស្ស នាយកសាលា និងបុគ្គលិកផ្សេងៗទៀត អំពីវិធីប្រាស្រ័យទាក់ទង និង សហការ ជាមួយមាតាបិតា ដែលជាដៃគូស្មើភាពគ្នា ឲ្យតម្លៃ និង ប្រើប្រាស់ ការបរិច្ចាគរបស់មាតាបិតា និងការអនុវត្តន៍ និងចាត់ចែងកម្មវិធី សម្រាប់មាតាបិតា ព្រមទាំងបណ្តុះចំណងមិត្តភាពរវាង មាតាបិតា និង សាលា ដោយ៖

**រៀបចំ អង្គប្រជុំ និង សិក្ខាសាលា ប្រចាំខែ ដែលមានប្រធានបទដែលពួកគាត់មានចំណាប់អារម្មណ៍ បានមកតាមរយៈការស្ទង់មតិពីមាតាបិតា។**

ឃ. <u>**សាលា យើងប្រាយ**</u> តាមតែអាចធ្វើទៅបាន និងលក្ខណៈសមរម្យ នឹង រៀបចំ និង បញ្ចូល កម្មវិធីចូលរួមរបស់មាតាបិតា និងសកម្មភាពផ្សេងៗជាមួយកម្មវិធី Head Start, Reading First, Early Reading First, Even Start, កម្មវិធីបង្ហាត់បង្រៀននៅផ្ទះ សម្រាប់កុមារមុនថ្នាក់មត្តេយ្យ កម្មវិធីមាតាបិតាជាគ្រូ និង ថ្នាក់មុនមត្តេយ្យរបស់រដ្ឋ និងកម្មវិធីផ្សេងៗទៀត ព្រមទាំងរៀបចំសកម្មភាពផ្សេងៗទៀត ដូចជា មណ្ឌលផ្តល់ព័ត៌មានសម្រាប់មាតាបិតា ដែលអាចជួយលើកទឹកចិត្ត និងអាចគាំទ្រដល់មាតាបិតា ឲ្យមានការចូលរួមឲ្យបានពេញលេញក្នុងការអប់រំកូន ដោយ៖

**រៀបចំ អង្គប្រជុំ និង សិក្ខាសាលា ប្រចាំខែ ដែលមានប្រធានបទដែលពួកគាត់មានចំណាប់អារម្មណ៍ បានមកតាមរយៈការស្ទង់មតិពីមាតាបិតា។ ផ្តល់ព័ត៌មានដល់មាតាបិតា តាមរយៈប្រត្តិប័ត្រសម្រាប់មាតាបិតា ប្រចាំខែ។**

ង. <u>**សាលា យើងប្រាយ**</u> នឹងធ្វើសកម្មភាពដូចតទៅនេះ ដើម្បីធ្វើយ៉ាងណាឲ្យព័ត៌មានដែលទាក់ទងនឹង កម្មវិធីដែលទាក់ទងនឹង សាលា និង មាតាបិតា អង្គប្រជុំ និង សកម្មភាពផ្សេងៗ ត្រូវផ្ញើទៅជូនមាតាបិតារបស់ក្មេងដែលបានចូលរួម តាមលក្ខណៈងាយយល់ និង មានទម្រង់ដូចគ្នា ដោយមានរួមទាំង ទម្រង់ផ្សេងៗទៀត តាមសេចក្តីស្នើ និង ជាភាសាដែលមាតាបិតាអាចយល់បាន ប្រសិនជាអាចធ្វើទៅបាន៖

**លិខិតទាក់ទងទាំងអស់នឹងផ្ញើទៅផ្ទះ ជាភាសាដែលនិយាយនៅផ្ទះ**

## <u>ផ្នែកទី III</u> <u>ផ្នែកផ្សេងៗនៃច្បាប់សម្រាប់ការចូលរួមរបស់មាតាបិតាទូទាំងសាលា</u>

<u>កំណត់សម្គាល់</u>៖ ច្បាប់នៃការចូលរួមសម្រាប់មាតាបិតារបស់សាលា អាចរួមបញ្ចូល វគ្គ និង ការអធិប្បាយ អំពីសកម្មភាពបន្ថែមផ្សេងៗទៀត តាមរយៈការពិគ្រោះជាមួយមាតាបិតា ដែលសាលាជ្រើសរើសអនុវត្ត ដើម្បីបង្កើនចំនួននៃការចូលរួមរបស់មាតាបិតានៅ សាលា និង ប្រព័ន្ធសាលា ដើម្បីជួយក្មេងឲ្យមានជោគជ័យក្នុងការសិក្សា ដូចជា សកម្មភាពបន្ថែមផ្សេងៗទៀតដែលបានចុះក្នុងបញ្ជី ក្រោមមាត្រា១១១៨(e) នៃច្បាប់ ESEA៖

- ឲ្យ មាតាបិតា ចូលរួមក្នុងការអភិវឌ្ឍន៍ការហ្វឹកហ្វឺន គ្រូ នាយកសាលា និង បញ្ញវន្តផ្សេងៗទៀត ដើម្បីបង្កើនប្រសិទ្ធិភាពនៃការហ្វឹកហ្វឺន
- ផ្តល់ការហ្វឹកហ្វឺនដែលចាំបាច់ផ្នែកអក្សរសាស្ត្រ ដល់មាតាបិតា តាមរយៈប្រាក់ឧបត្ថម្ភពីច្បាប់ Title I, Part A បើសិនជាក្រសួងអប់រំអស់ថវិការសម្រាប់ការហ្វឹកហ្វឺនទាំងនោះ
- បង់ថ្លៃចំណាយ តាមលក្ខណៈសមរម្យ និងចាំបាច់ ដែលទាក់ទងនឹងសកម្មភាពនៃការចូលរួមរបស់មាតាបិតា រួមទាំងការដឹកជញ្ជូន ដើម្បីឲ្យមាតាបិតា មានលទ្ធភាពចូលរួមក្នុងអង្គប្រជុំដែលទាក់ទងនឹងសាលា និង ការហ្វឹកហ្វឺនផ្សេងៗ
- ហ្វឹកហ្វឺនមាតាបិតា ដើម្បីឲ្យជួយបង្កើនការចូលរួមពីមាតាបិតា ផ្សេងៗទៀត
- រៀបចំអង្គប្រជុំនៅសាលាតាមពេលវេលាខុសៗគ្នា ឬជួបប្រជុំនៅក្នុងផ្ទះ រវាង គ្រូ ឬ អ្នកអប់រំផ្សេងទៀត ដែលធ្វើការជាមួយក្មេងដែលចូលរួម និងមាតាបិតាដែលមិនអាចចូលរួមប្រជុំនៅសាលាបាន ដើម្បីបង្កើនការចូលរួមរបស់មាតាបិតា ក្នុងការអប់រំរបស់កូន ឲ្យបានកាន់តែច្រើន។

- អនុម័ត និង អនុវត្ត តាមគំរូណាដែលអាចជួយបង្កើននូវការចូលរួមរបស់មាតាបិតា។
- បង្កើតក្រុមប្រឹក្សាសាលាទូទាំងក្រសួង ដើម្បីផ្តល់យោបល់ទៅលើអ្វីៗ ដែលទាក់ទងនឹងការចូលរួមរបស់មាតាបិតា ក្នុងកម្មវិធីរបស់ច្បាប់ Title I, Part A។
- បង្កើតឲ្យមានតួនាទីសមរម្យសម្រាប់ អង្គការនៅក្នុងសហគមន៍ និង ពាណិជ្ជកម្មផ្សេងៗ រួមទាំង អង្គការសាសនា ក្នុងសកម្មភាពនៃការចូលរួមរបស់មាតាបិតា និង
- ផ្តល់ជំនួយដែលសមហេតុសមផលផ្សេងៗ ដល់សកម្មភាពនៃការចូលរួមរបស់មាតាបិតា តាមមាត្រាលេខ ១១១៨ តាមការស្នើសុំរបស់ មាតាបិតា។

* * * * *

## <u>ផ្នែកទី IV</u> <u>ការអនុម័ត</u>

ច្បាប់នៃការចូលរួមរបស់មាតាបិតា របស់ **<u>សាលា ឃើតប្រាយ</u>** នេះ បានរួមគ្នាបង្កើតជាមួយ និង មានការយល់ព្រមពី មាតាបិតា ដោយភ័ស្តុតាងបញ្ជាក់ពីអ្នកស្រី <u>Sharon Parto ប្រធានសមាគម មាតាបិតា និង សាលា (Home & School President)</u>។

សាលានឹងចែកច្បាប់នេះជូនទៅមាតាបិតាទាំងអស់ ឲ្យបានមុនថ្ងៃ ឬនៅថ្ងៃ **<u>ទី៣០ ខែកញ្ញា ឆ្នាំ២០១៤</u>**។

____________________________________
*(ហត្ថលេខារបស់នាយកសាលា/Signature of Principal)*

____________________________________
(ថ្ងៃខែ/Date)